## United States District Court For The Northern District Of California

### បើលោកអ្នកនៅក្នុងកម្មវិធី Medi-Cal ហើយកំពុងតែទទួល (ឬធ្លាប់ទទួលពេលថ្មីៗនេះ) នូវ Adult Day Health Care (ADHC) (ការថែទាំសុខភាពពេលថ្ងៃសម្រាប់ជនពេញវ័យ) សំបុត្រនេះគឺជា Notice of a Class Action Settlement (សេចក្តីជូនដំណឹងអំពីការផ្សះផ្សាបណ្តឹងតាងនាមក្រុម) ដែលអាចមានផលប៉ះពាល់ដល់រូបលោកអ្នក ។

*តុលាការសហព័ន្ធមួយបានអនុញ្ញាតសេចក្តីជូនដំណឹងនេះ ។ នេះមិនមែនជាការបញ្ចូលចិត្តមកពីមេធាវីឡើយ ។*

បណ្តឹងមួយត្រូវបានដាក់ ស្នើសុំឲ្យតុលាការបញ្ឈប់រដ្ឋ California មិនឲ្យបញ្ចប់កម្មវិធី Medi-Cal ADHC លុះត្រាតែមានការបង្កើតសេវាកម្មផ្សេងទៀតជំនួស សម្រាប់អ្នកដែលទទួលសេវាកម្ម ADHC ។ ភាគីទាំងឡាយនៃបណ្តឹងនេះបានឈានដល់ការផ្សះផ្សាបណ្តឹងហើយ ។ បើតុលាការអនុម័តការផ្សះផ្សា កម្មវិធី ADHC នឹងត្រូវចប់នៅថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2012 ។ ចាប់ពីថ្ងៃទី 1 ខែមិនា ឆ្នាំ 2012 លោកអ្នកនឹងទទួលសេវាកម្មផ្សេងទៀត អាស្រ័យលើស្ថានភាពរបស់លោកអ្នក ។ ខាងក្រោមនេះមានការពិពណ៌នាពេញលេញ អំពីសេវាកម្មដែលនឹងផ្តល់ជូន ហើយអ្នកណានឹងមានសិទ្ធិទទួលសេវាកម្មនីមួយៗ ។ ខាងក្រោមនេះក៏មានព័ត៌មានអំពីកិច្ចព្រមព្រៀងផ្សះផ្សា ដែលគួរនឹងឆ្លើយសំនួរណាដែលលោកអ្នកមានអំពីកិច្ចព្រមព្រៀងនោះ ហើយនិងកន្លែងដើម្បីទាក់ទង បើលោកអ្នកមានសំនួរបន្ថែមទៀត ។

ការផ្សះផ្សានេះនឹងមិនប៉ះពាល់ដល់សមត្ថភាពដើម្បីបន្តជួបនឹងគ្រូពេទ្យថែទាំចម្បងរបស់លោកអ្នកឡើយ បើលោកអ្នកកំពុងចូលរួមក្នុងកម្មវិធី Medicare ។ សេវាកម្មដែលមានផ្តល់ជូននៅក្រោមកិច្ចព្រមព្រៀងផ្សះផ្សា គឺបន្ថែមទៅលើសេវាកម្មដែលលោកអ្នកកំពុងទទួលតាមរយៈ Medicare ។

បណ្តឹងនេះ មិនមែនជាបណ្តឹងសុំសំណងជាប្រាក់នោះឡើយ ។

តុលាការនៅតែត្រូវសម្រេចថាតើអនុម័ត ឬមិនអនុម័តកិច្ចព្រមព្រៀងផ្សះផ្សា ។

**សេចក្តីជូនដំណឹងនេះពន្យល់នូវសិទ្ធិ និងជម្រើសនានារបស់លោកអ្នក – ហើយនិងថ្ងៃខែកំណត់ ដើម្បីអនុវត្តវា ។ សូមអានសេចក្តីជូនដំណឹងនេះឲ្យបានប្រុងប្រយ័ត្ន ។**

| សិទ្ធិ និងជម្រើសផ្លូវច្បាប់របស់លោកអ្នក នៅក្នុងការផ្សះផ្សានេះ | |
|---|---|
| **មិនធ្វើអ្វីឡើយ** | បើលោកអ្នកមិនធ្វើអ្វីឡើយ តុលាការនឹងវាយតម្លៃការផ្សះផ្សាដោយគ្មានការសង្កេតអ្វីពីលោកអ្នក ។ លោកអ្នកនឹងលះបង់ចោលសិទ្ធិដើម្បីតវ៉ាចំពោះការបញ្ចប់កម្មវិធី ADHC នៅក្នុងបណ្តឹងផ្សេងទៀត ។ បើលោកអ្នកកំពុងទទួលសេវាកម្ម ADHC ឥឡូវនេះ លោកអ្នកមិនចាំបាច់ឆ្លើយតបនឹងសេចក្តីជូនដំណឹងនេះ ដើម្បីទទួលសេវាកម្មដែលបង្កើតឡើងដោយការផ្សះផ្សានេះឡើយ ។ |
| **តវ៉ាជាលាយលក្ខណ៍អក្សរ ឲ្យបានទាន់ថ្ងៃទី 10 ខែមករា ឆ្នាំ 2012** | សរសេរសំបុត្រទៅកាន់តុលាការស្តីអំពីមូលហេតុដែលលោកអ្នកមិនចូលចិត្តការផ្សះផ្សា ។ មិនតែប៉ុណ្ណោះ លោកអ្នក អាចស្នើសុំនិយាយក្នុងតុលាការអំពីការតវ៉ារបស់លោកអ្នក ។ ការតវ៉ារបស់លោកអ្នកត្រូវតែផ្ញើទៅតុលាការឲ្យបានទាន់ថ្ងៃទី 10 ខែមករា ឆ្នាំ 2012 ដើម្បីទទួលការពិចារណា។ |
| **ទៅចូលរួមក្នុងសវនាការ Fairness Hearing (សវនាការយុត្តិធម៌) នៅថ្ងៃទី 24 ខែមករា ឆ្នាំ 2012** | បើលោកអ្នកចង់និយាយនៅក្នុង Fairness Hearing ត្រូវតែប្រាកដនិយាយនៅក្នុងសំបុត្រទៅតុលាការ ។ម្យ៉ាងទៀត លោកអ្នកមិនត្រូវតែបង្ហាញខ្លួននៅឯ Fairness Hearing ដើម្បីឲ្យការតវ៉ារបស់លោកអ្នកទទួលការពិចារណាឡើយ ។ |

# NOTICE OF CLASS ACTION SETTLEMENT AGREEMENT
# (សេចក្ដីជូនដំណឹងអំពីកិច្ចព្រមព្រៀងផ្សះផ្សាបណ្ដឹងតាងនាមក្រុម)
# *Darling et al. v. Douglas et al.*, C09-03798 SBA

## 1. ហេតុអ្វីបានជាខ្ញុំទទួលសេចក្ដីជូនដំណឹងនេះ ?

លោកអ្នកទទួលសេចក្ដីជូនដំណឹងនេះ ដោយសារលោកអ្នកកំពុងទទួល ឬធ្លាប់ទទួលតាំងពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2011 នូវសេវាកម្ម Medi-Cal Adult Day Health Care (ADHC) ហើយត្រូវបានរាប់ទុកជាសមាជិកក្រុម នៅក្នុងបណ្ដឹងនេះ ។

លោកអ្នកមានសិទ្ធិដើម្បីដឹងអំពីការផ្សះផ្សានៃបណ្ដឹងតាងនាមក្រុមដែលបានលើកឡើង ហើយអំពីជម្រើសរបស់លោកអ្នក មុនតុលាការសម្រេចថាតើអនុម័ត ឬមិនអនុម័តការផ្សះផ្សា ។ សេចក្ដីជូនដំណឹងនេះពន្យល់អំពីបណ្ដឹង អ្វីដែលសមាជិកក្រុមនឹងទទួលបើតុលាការអនុម័តការផ្សះផ្សា ហើយនិងសិទ្ធិផ្លូវច្បាប់របស់លោកអ្នកទាក់ទងនឹងការផ្សះផ្សា ។

តុលាការដែលគ្រប់គ្រងរឿងក្ដីនេះ គឺ United States District Court for the Northern District of California ។ រឿងក្ដីនេះឈ្មោះថា *Darling et al. v. Douglas et al.*។ លេខរឿងក្ដីគឺ C09-03798 SBA ។ អ្នកចូលរួម ADHC ទាំងប្រាំពីរនាក់ដែលបានដាក់ពាក្យប្ដឹង ហៅថាភាគីដើមចោទ ហើយភាគីចុងចោទគឺជា Department of Health Care Services (DHCS) ហើយនិង Director គឺលោក Toby Douglas ។ គ្រប់បុគ្គលផ្សេងទៀតដែលទទួលសេវាកម្ម ADHC ហៅថា សមាជិកក្រុម ។

## 2. តើបណ្ដឹងនេះស្ដីអំពីរឿងអ្វី ?

នៅក្នុងឆ្នាំ 2009 អ្នកខ្លះដែលទទួល Medi-Cal Adult Day Health Care (ADHC) (ភាគីដើមចោទ) បានដាក់ពាក្យប្ដឹងភាគីចុងចោទ ។ ពួកគេបានស្នើសុំតុលាការឲ្យបញ្ឈប់ភាគីចុងចោទ មិនឲ្យបន្ថយសេវាកម្ម ADHC ហើយតុលាការបានអនុវត្តតាម ។ នៅក្នុងឆ្នាំ 2011 ភាគីដើមចោទបានស្នើសុំតុលាការឲ្យបញ្ឈប់ភាគីចុងចោទមិនឲ្យបញ្ចប់អត្ថប្រយោជន៍ ADHC ទាំងស្រុង ។ ពួកគេបានលើកហេតុផលថា បើភាគីចុងចោទមិនផ្ដល់សេវាកម្មជំនួសADHCទេ នោះការបញ្ចប់កម្មវិធីនឹងបំពានលើច្បាប់ Americans with Disabilities Act (ADA) ហើយនិងច្បាប់ផ្សេងៗទៀត ។ ភាគីចុងចោទខាងរដ្ឋបដិសេធការលើកហេតុផលនេះ ។

## 3. ហេតុអ្វីបានជារឿងនេះជាបណ្ដឹងតាងនាមក្រុម ?

នៅក្នុងបណ្ដឹងតាងនាមក្រុម មនុស្សម្នាក់ ឬច្រើនជាងម្នាក់ ហៅថាតំណាងក្រុម ឬហៅភាគីដើមចោទ ដាក់ពាក្យប្ដឹងតាងនាមនៃមនុស្សដែលមានការទាមទារស្រដៀងគ្នា ។ មនុស្សទាំងអស់នេះ គឺជាសមាជិកក្រុម ។ តុលាការមួយដោះស្រាយរឿងរ៉ាវសម្រាប់សមាជិកក្រុមទាំងអស់គ្នា ។ នៅក្នុងរឿងក្ដីនេះ Esther Darling ហើយនិងអ្នកដើមចោទឈ្មោះផ្សេងៗទៀត បានប្ដឹងតាងនាមអ្នកទាំងអស់គ្នាដែលទទួលអត្ថប្រយោជន៍ Medi-Cal ADHC ។ ការសម្រេចណារបស់តុលាការក្នុងរឿងក្ដីនេះ នឹងមានផលប៉ះពាល់ដល់សមាជិកក្រុមគ្រប់រូប ។

## 4. ហេតុអ្វីបានជាមានការផ្សះផ្សា ?

ភាគីដើមចោទ និងភាគីចុងចោទបានយល់ព្រមគ្នាធ្វើការផ្សះផ្សាមួយ ដែលក្នុងនោះគេបានសហការបង្កើតកម្មវិធីថ្មី ដើម្បីជំនួសកម្មវិធីADHC ។ តំណាងក្រុម និងមេធាវីរបស់ភាគីដើមចោទគិតថា ការផ្សះផ្សានេះ គឺយុត្តិធម៌ហើយ ។ **Fairness Hearing មួយដើម្បីអនុម័តការផ្សះផ្សាចុងក្រោយ នឹងប្រព្រឹត្តទៅឡើងនៅក្នុងសាលាក្ដី U.S. District Court នៅក្នុងទីក្រុង Oakland នៅថ្ងៃទី 24 ខែមករា ឆ្នាំ 2012 នៅវេលាម៉ោង 1 រសៀល ។ សូមមើលសំនួរលេខ 14-17 ខាងក្រោមនេះ សម្រាប់ព័ត៌មានបន្ថែមអំពីសវនាការតុលាការនោះ ។**

# NOTICE OF CLASS ACTION SETTLEMENT AGREEMENT
# (សេចក្ដីជូនដំណឹងអំពីកិច្ចព្រមព្រៀងផ្សះផ្សាបណ្ដឹងតាងនាមក្រុម)
# *Darling et al. v. Douglas et al.*, C09-03798 SBA

### 5. តើធ្វើដូចម្ដេចឲ្យដឹងថា ខ្ញុំមានចំណែកនៅក្នុងការផ្សះផ្សានេះ ?

លោកអ្នកគឺជាសមាជិកក្រុម ហើយមានចំណែកនៅក្នុងការផ្សះផ្សានេះ បើលោកអ្នកបំពេញលក្ខខណ្ឌខាងក្រោមៈ ៖

> "អ្នកទទួលអត្ថប្រយោជន៍ Medi-Cal គ្រប់រូបនៅក្នុង State of California ដែលអត្ថប្រយោជន៍ Adult Day Health Care របស់គេត្រូវបានផ្ដាច់ចោលនៅក្រោមច្បាប់ Assembly Bill 97 (AB 97) រួមទាំងអ្នកដែលបំពេញ ឬដែលនឹងបំពេញ នូវលក្ខខណ្ឌខាងផ្នែកសិទ្ធិចូលរួម និងភាពចាំបាច់ខាងផ្នែកវេជ្ជសាស្ត្របច្ចុប្បន្ន សម្រាប់កម្មវិធី ADHC នៅពេលណាមួយមុនថ្ងៃខែឆ្នាំដែលការផ្សះផ្សានេះចាប់មានសុពលភាព ឬដែលនឹងបំពេញលក្ខខណ្ឌខាងផ្នែកសិទ្ធិចូលរួម និងភាពចាំបាច់ខាងផ្នែកវេជ្ជសាស្ត្រ សម្រាប់កម្មវិធី Community Based Adult Services (CBAS) នៅពេលណាមួយ មុនការផ្ដាច់កិច្ចព្រមព្រៀងនេះ ។"

នេះមានន័យថា លោកអ្នកមានចំណែកក្នុងការផ្សះផ្សានេះ បើសិនជាអត្ថប្រយោជន៍ Medi-Cal ADHC របស់លោកអ្នកត្រូវបានផ្ដាច់ចោលដោយច្បាប់ AB 97 ឬបើសិនជាលោកអ្នកនឹងចាប់មានសិទ្ធិចូលរួមក្នុងកម្មវិធី ADHC មុនថ្ងៃទី 1 ខែមិនា ឆ្នាំ 2012 ។ វាក៏មានន័យថា អ្នកណាដែលមានសិទ្ធិចូលរួមក្នុងកម្មវិធីថ្មី គឺ CBAS មានចំណែកក្នុងការផ្សះផ្សានេះដែរ ។ AB 97 គឺជាច្បាប់ថ្មីមួយ ដែលផ្ដាច់ចោលកម្មវិធី ADHC ជាអត្ថប្រយោជន៍ Medi-Cal ។

### 6. តើការផ្សះផ្សានេះផ្ដល់អ្វីខ្លះ ?

ក្រោមកិច្ចព្រមព្រៀងផ្សះផ្សា ក្រសួង DHCS នឹងបង្កើតកម្មវិធី Medi-Cal ថ្មីមួយ ហៅថា Community Based Adult Services (CBAS) ។

- CBAS អនុញ្ញាតអស់អ្នកណាក្នុង Medi-Cal ដែលមានសិទ្ធិចូលរួម ឲ្យទទួលការថែទាំគិលានុបដ្ឋាយិកាជំនាញ សេវាសង្គមកិច្ច ការព្យាបាល ការថែទាំផ្ទាល់ខ្លួន ការបណ្ដុះបណ្ដាលនិងគាំទ្រគ្រួសារ/អ្នកថែទាំ អាហារ ការដឹកជញ្ជូន និងការគ្រប់គ្រងសំណុំរឿង នៅទីតាំងកណ្ដាលតែមួយកន្លែង ។
- CBAS នឹងត្រូវបានផ្ដល់ជូននៅឯអតីតមជ្ឈមណ្ឌល ADHC មួយចំនួន ដែលបានអនុម័តដោយក្រសួង DHCS ដើម្បីជាកន្លែងផ្ដល់សេវាកម្ម CBAS ។
- CBAS នឹងចាប់ផ្ដើមនៅថ្ងៃទី 1 ខែមិនា ឆ្នាំ 2012 ។

កិច្ចព្រមព្រៀងផ្សះផ្សានឹងបង្កើត "ការគ្រប់គ្រងសំណុំរឿងប្រសើរឡើង" សម្រាប់អស់អ្នកណាដែលធ្លាប់ប្រើ ADHC ប៉ុន្តែមិនមានសិទ្ធិចូលរួមក្នុង CBAS ។

- ការគ្រប់គ្រងសំណុំរឿងប្រសើរឡើង នឹងជួយអ្នកដែលមានសិទ្ធិចូលរួមដើម្បីទទួលសេវាកម្មផ្នែកសុខភាព និងផ្នែកសង្គមកិច្ច ដែលគេត្រូវការ នៅពេលដែល ADHC ចប់ហើយ ។ លោកអ្នកនឹងមានសំឡេងក្នុងការសម្រេចអំពីសេវាកម្មដែលគេទទួលបាន នឹងរបៀបដែលគេទទួលវា ។

សេវាកម្ម ADHC នឹងបន្តរហូតដល់ថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2012 ដើម្បីផ្ដល់ពេលវេលាឲ្យមនុស្សផ្លាស់ប្ដូរពីការទទួលសេវាកម្មពីអ្នកផ្ដល់សេវាកម្ម ADHC ទៅការទទួលសេវាកម្មពីអ្នកផ្ដល់សេវាកម្ម CBAS វិញ ឬដើម្បីចាប់ផ្ដើមទទួលសេវាកម្មគ្រប់គ្រងសំណុំរឿងប្រសើរឡើង ។ សមាជិកក្រុមគ្រប់រូបនឹងទទួលCBAS ឬការគ្រប់គ្រងសំណុំរឿងប្រសើរឡើង ។

រឿងក្ដីនេះមិនមែនជាបណ្ដឹងស្នើសុំសំណងជាប្រាក់ឡើយ ដូច្នេះគ្មានអ្នកដើមចោទ ឬសមាជិកក្រុមណាម្នាក់ទទួលការបង់ប្រាក់ ដោយរួមចំណែកក្នុងបណ្ដឹងនេះឡើយ ។

# NOTICE OF CLASS ACTION SETTLEMENT AGREEMENT
# (សេចក្តីជូនដំណឹងអំពីកិច្ចព្រមព្រៀងផ្សះផ្សាបណ្តឹងតាងនាមក្រុម)
# *Darling et al. v. Douglas et al.,* C09-03798 SBA

## 7. តើអ្វីនឹងកើតឡើងចំពោះរូបខ្ញុំ ក្រោមកិច្ចព្រមព្រៀងផ្សះផ្សា ?

- បើលោកអ្នកមាន Medi-Cal ហើយ កំពុង ចូលរួមក្នុង ADHC ឥឡូវនេះ ៖
  - លោកអ្នកនឹងត្រូវបានវាយតម្លៃសម្រាប់ CBAS នៅពេលណាមួយ រវាងខែធ្នូ ឆ្នាំ 2011 និងខែកុម្ភៈ ឆ្នាំ 2012 ។ អ្នកផ្តល់សេវាកម្ម ADHC របស់លោកអ្នក នឹងផ្តល់ព័ត៌មានបន្ថែមទៀតឲ្យលោកអ្នក ស្តីអំពីដំណើរការវាយតម្លៃ ។
  - បើលោកអ្នកមានសិទ្ធិចូលរួមក្នុង CBAS លោកអ្នកនឹងចាប់ទទួលសេវាកម្មទាំងនេះភ្លាម នៅពេលដែលសេវាកម្ម ADHC ចប់ នៅថ្ងៃទី 1 ខែមិនា ឆ្នាំ 2012 ។
  - បើលោកអ្នកមិនមានសិទ្ធិចូលរួមក្នុង CBAS ទេ នោះថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2012 ជាថ្ងៃចុងក្រោយដែលលោកអ្នកនឹងទទួលសេវាកម្ម ADHC ។ លោកអ្នកនឹងទទួលសេវាកម្មគ្រប់គ្រងសំណុំរឿងប្រសើរឡើង ដើម្បីជួយលោកអ្នកផ្លាស់ប្តូរទៅកាន់សេវាកម្មផ្សេងទៀត ដែលលោកអ្នកត្រូវការ ។
- បើលោកអ្នកមាន Medi-Cal ហើយ ប៉ុន្តែ មិន ចូលរួមក្នុង ADHC ឥឡូវនេះ ៖
  - លោកអ្នកនៅតែអាចដាក់ពាក្យសុំ ADHC រហូតដល់ថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2012 ។
  - លោកអ្នកអាចស្នើសុំឲ្យគេវាយតម្លៃលោកអ្នក សម្រាប់ CBAS បាន ។

## 8. តើធ្វើដូចម្តេចឲ្យដឹងថាតើខ្ញុំមានសិទ្ធិចូលរួមក្នុង CBAS ?

លោកអ្នកអាចទទួល CBAS បាន បើលោកអ្នកកំពុងនៅក្នុង Medi-Cal **និង** មានសិទ្ធិចូលរួមក្នុង ADHC **និង** ៖

- ត្រូវការសេវាកម្មគិលានុបដ្ឋាយិកាល្មមនឹងបំពេញត្រឹម "Nursing Facility Level of Care A" (NF-A) ឬខ្ពស់ជាង; **ឬ**
- មានពិការភាពផ្លូវគំនិតកម្រិតមធ្យម ទៅធ្ងន់ រួមទាំងជំងឺ Alzheimer's Disease ឬជំងឺវិកលចរិតផ្សេងទៀតកម្រិតមធ្យមទៅធ្ងន់ **ឬ**
- មានពិការភាពផ្នែកលូតលាស់; **ឬ**
- មានពិការភាពផ្លូវគំនិតកម្រិតស្រាល ទៅមធ្យម រួមទាំងជំងឺ Alzheimer's ឬជំងឺវិកលចរិតផ្សេងទៀត **និង**ត្រូវការជំនួយ ឬការត្រួតមើល ក្នុងសកម្មភាពដូចទៅនេះចំនួនពីរ ៖ ការមុជទឹក ការស្លៀកពាក់ ការទទួលទានអាហារដោយខ្លួនឯង ការប្រើបង្គន់ ការដើរ ការប្តូរកន្លែង ការគ្រប់គ្រងថ្នាំពេទ្យ ឬការរក្សាអនាម័យផ្ទាល់ខ្លួន; **ឬ**
- មានជំងឺផ្លូវចិត្តរ៉ាំរ៉ៃ ឬរបួសខួរក្បាល **និង**ត្រូវការជំនួយ ឬការត្រួតមើល ក្នុងសកម្មភាពដូចទៅនេះចំនួនពីរ ៖ ការមុជទឹក ការស្លៀកពាក់ ការទទួលទានអាហារដោយខ្លួនឯង ការប្រើបង្គន់ ការដើរ ការប្តូរកន្លែង ការគ្រប់គ្រងថ្នាំពេទ្យ ឬការរក្សាអនាម័យផ្ទាល់ខ្លួន; **ឬ** សកម្មភាពមួយក្នុងបញ្ជីខាងលើ ហើយសកម្មភាពមួយទៀតដូចតទៅនេះ ៖ ការគ្រប់គ្រងលុយ ការប្រើប្រាស់ធនធាន ការរៀបចំអាហារ និងមធ្យោបាយដឹកជញ្ជូន ។

# NOTICE OF CLASS ACTION SETTLEMENT AGREEMENT
# (សេចក្តីជូនដំណឹងអំពីកិច្ចព្រមព្រៀងផ្សះផ្សាបណ្តឹងតាងនាមក្រុម)
# *Darling et al. v. Douglas et al.*, C09-03798 SBA

### 9. បើខ្ញុំត្រូវបានវាយតម្លៃហើយកំណត់ថាមានសិទ្ធិចូលរួម តើខ្ញុំនឹងទទួល CBAS ដោយស្វ័យប្រវត្តិ មែនឬ ?

មែន ។ នៅពេលដែលអ្នកត្រូវបានកំណត់ថា មានសិទ្ធិចូលរួមក្នុង CBAS ហើយ លោកអ្នកនឹងទទួលការណែនាំអំពីរបៀបដើម្បីចុះឈ្មោះ បើមានមជ្ឈមណ្ឌល CBAS នៅក្នុងតំបន់ដែលលោកអ្នករស់នៅ ។ បើគ្មានមជ្ឈមណ្ឌល CBAS នៅក្នុងតំបន់ដែលលោកអ្នករស់នៅទេ លោកអ្នកអាចទទួលសេវាកម្មដូចគ្នាដែលផ្តល់ជូនក្នុងមជ្ឈមណ្ឌល CBAS ប៉ុន្តែទទួលពីអ្នកផ្តល់សេវាកម្មផ្សេងទៀត ។

- រវាងថ្ងៃទី 1 ខែមិនា ឆ្នាំ 2012 និងប្រហែលថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2012 CBAS នឹងត្រូវបានផ្តល់ជូនតាមរយៈ Medi-Cal ធម្មតា ។ យូរៗទៅ CBAS នឹងត្រូវបានផ្តល់ជូនច្រើនតែតាមរយៈគម្រោងគ្រប់គ្រងការថែទាំMedi-Cal វិញ ។
- នៅពេលដែល CBAS ត្រូវបានផ្តល់ជូនច្រើនតែតាមរយៈគម្រោងគ្រប់គ្រងការថែទាំ Medi-Cal ហើយ បើលោកអ្នករស់នៅក្នុងស្រុកដែលផ្តល់គម្រោងគ្រប់គ្រងការថែទាំ Medi-Cal ហើយលោកអ្នកមានសិទ្ធិចូលរួមក្នុងគម្រោងគ្រប់គ្រងការថែទាំមួយ ពេលនោះទើបលោកអាចទទួល CBAS បាន តាមរយៈតែគម្រោងគ្រប់គ្រងការថែទាំប៉ុណ្ណោះ ។
  - បើលោកអ្នកចុះឈ្មោះក្នុងគម្រោងគ្រប់គ្រងការថែទាំ Medi-Cal នៅពេលណាមួយមុនថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2012 ឬបើលោកអ្នកបានចុះឈ្មោះក្នុងគម្រោងគ្រប់គ្រងការថែទាំ Medi-Cal មួយស្រាប់ហើយ គម្រោងគ្រប់គ្រងការថែទាំរបស់លោកអ្នកនឹងបង់ប្រាក់សម្រាប់ CBAS នៅពេលវាក្លាយជាជម្រើសមួយ នៃគម្រោងគ្រប់គ្រងការថែទាំហើយ ។ លោកអ្នកមិនចាំបាច់ធ្វើការផ្លាស់ប្តូរណាដើម្បីបន្តទទួល CBAS ឡើយ ។
  - បើអ្នកអាចចុះឈ្មោះក្នុងគម្រោងគ្រប់គ្រងការថែទាំ Medi-Cal បាន ប៉ុន្តែឥឡូវនេះមិនទាន់បានចុះឈ្មោះ លោកអ្នកត្រូវតែចុះឈ្មោះដើម្បីបន្តទទួល CBAS នៅពេលគេចាប់ផ្តើមផ្តល់ជូនវាតាមរយៈគម្រោងគ្រប់គ្រងការថែទាំ Medi-Cal ។
  - បើលោកអ្នកទទួល Medicare ការចុះឈ្មោះក្នុងគម្រោងគ្រប់គ្រងការថែទាំ Medi-Cal **នឹងមិន** ប៉ះពាល់ដល់សមត្ថភាពរបស់លោកអ្នក ដើម្បីជ្រើសរើសគ្រូពេទ្យ Medicare របស់លោកអ្នកឡើយ ។
- បើលោកអ្នករស់នៅក្នុងស្រុកមួយដែលមិនមានគម្រោងគ្រប់គ្រងការថែទាំ Medi-Cal ឬបើលោកអ្នកមិនអាចចូលរួមគម្រោងគ្រប់គ្រងការថែទាំបានទេ លោកអ្នកមិនចាំបាច់ធ្វើការផ្លាស់ប្តូរអ្វីឡើយ ដើម្បីបន្តទទួល CBAS ។ លោកអ្នកអាចបន្តទទួល CBAS ជាអត្ថប្រយោជន៍ Medi-Cal ធម្មតាបាន ។

### 10. តើខ្ញុំនិងអាចទៅមជ្ឈមណ្ឌលដដែល ដើម្បីទទួល CBASបានទេ ?

មិនទៀងទេ ។ មជ្ឈមណ្ឌល ADHC ជាច្រើនកន្លែងនឹងនៅតែមានសមត្ថភាពផ្តល់ CBAS ។ មជ្ឈមណ្ឌល ADHC អាចដាក់ពាក្យសុំរដ្ឋឲ្យក្លាយជាកន្លែងផ្តល់សេវាកម្ម CBAS បាន ។ បើលោកអ្នកមានសិទ្ធិចូលរួមក្នុង CBAS ហើយ មជ្ឈមណ្ឌល ADHC របស់លោកអ្នកត្រូវបានអនុម័តជាកន្លែងផ្តល់សេវាកម្ម CBAS ឲ្យបានទាន់ថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2012 នោះលោកអ្នកអាចបន្តទទួលសេវាកម្មនៅមជ្ឈមណ្ឌលដដែល នៅពេលកម្មវិធី ADHC ចប់ហើយ ។ បើមជ្ឈមណ្ឌល ADHC របស់លោកអ្នកមិនក្លាយជាកន្លែងផ្តល់សេវាកម្ម CBAS ទេ នោះលោកអ្នកនឹងត្រូវបានផ្តល់ព័ត៌មានអំពីកន្លែងផ្តល់សេវាកម្ម CBAS ផ្សេងទៀត ។

# NOTICE OF CLASS ACTION SETTLEMENT AGREEMENT
# (សេចក្តីជូនដំណឹងអំពីកិច្ចព្រមព្រៀងផ្សះផ្សាបណ្តឹងតាងនាមក្រុម)
# *Darling et al. v. Douglas et al.,* C09-03798 SBA

### 11. ចុះបើខ្ញុំអត់មានសិទ្ធិចូលរួមក្នុង CBAS តើយ៉ាងណាទៅ ?

បើលោកអ្នកកំពុងនៅក្នុង ADHC ប៉ុន្តែមិនមានសិទ្ធិចូលរួមក្នុង CBASទេ នោះ លោកអ្នកនឹងទទួលការគ្រប់គ្រងសំណុំរឿងប្រសើរឡើង ដើម្បីជួយលោកអ្នកទទួលសេវាកម្មសុខភាពនិងសង្គមកិច្ចដែលលោកអ្នកត្រូវការ ក្រោយពេលដែល ADHC ចប់ហើយ ។ អ្នកគ្រប់គ្រងសំណុំរឿងនៅក្នុងកម្មវិធីនេះនឹងពិភាក្សាជាមួយលោកអ្នក ដើម្បីឲ្យលោកអ្នកមានសំឡេងក្នុងសេវាកម្មដែលលោកអ្នកទទួល និងរបៀបដែលលោកអ្នកទទួលវា ។

លោកអ្នកនឹងមានការជ្រើសរើសដើម្បីទទួលការគ្រប់គ្រងសំណុំរឿងប្រសើរឡើង ជាសេវាកម្ម Medi-Cal ធម្មតា ឬតាមរយៈគម្រោងគ្រប់គ្រងការថែទាំ Medi-Cal ។

### 12. តើខ្ញុំមានមេធាវីក្នុងរឿងក្តីនេះឬទេ ?

មាន ។ អង្គការ Disability Rights California, National Senior Citizens Law Center, National Health Law Program, AARP Foundation Litigation, ហើយនិងក្រុមហ៊ុនច្បាប់ Morrison & Foerster LLP ត្រូវបានតុលាការអនុម័ត ដើម្បីធ្វើជាតំណាងលោកអ្នក ហើយនិងសមាជិកក្រុមឯទៀតៗ ។ រួមជាមួយគ្នា មេធាវីទាំងនេះហៅថា គណៈមេធាវីតំណាងក្រុម ។ លោកអ្នកនឹងមិនត្រូវគេទារប្រាក់សម្រាប់មេធាវីទាំងនេះឡើយ ។

### 13. តើមេធាវីទាំងនេះនឹងត្រូវបានបើកប្រាក់យ៉ាងដូចម្តេច ?

បើការផ្សះផ្សាត្រូវបានអនុម័ត ភាគីចុងចោទនឹងបង់ថ្លៃមេធាវីទៅកាន់មេធាវីរបស់ភាគីដើមចោទ សម្រាប់ការងាររបស់ពួកគេនៅក្នុងរឿងក្តីនេះ ។ តុលាការត្រូវតែអនុម័តចំនួននៃថ្លៃទាំងនោះ ។ ភាគីដើមចោទ និងភាគីចុងចោទនឹងស្នើសុំឲ្យតុលាការអនុម័តថ្លៃចំនួន $2.2 លាន សម្រាប់ការងារដែលបានធ្វើនៅក្នុងរយៈពេល 2-1/2 ឆ្នាំកន្លងមកនេះ ។ ពួកគេនឹងស្នើសុំឲ្យតុលាការអនុម័តដល់ទៅ $400,000 សម្រាប់មេធាវីរបស់ភាគីដើមចោទ ដើម្បីត្រួតមើលដំណើរនៃការផ្សះផ្សានៅក្នុងរយៈពេល 2-1/2 ឆ្នាំខាងមុខនេះ ។ លោកអ្នកមិនចាំបាច់បង់ប្រាក់សម្រាប់ពួកមេធាវីឡើយ ។

### 14. តើខ្ញុំមានជម្រើសអ្វីខ្លះ ចំពោះការផ្សះផ្សា ?

លោកអ្នកអាចមិនធ្វើអ្វីឡើយ ហើយលោកអ្នកនឹងនៅតែជាសមាជិកក្រុម ។ លោកអ្នកអាចសរសេរសំបុត្រទៅកាន់តុលាការថ្លែងហេតុផលដែលលោកអ្នកមិនចូលចិត្តការផ្សះផ្សា ហើយផ្ញើសំបុត្រឲ្យបានទាន់ថ្ងៃទី 10 ខែមករា ឆ្នាំ 2012 ។ បើលោកអ្នកចង់និយាយនៅក្នុង Fairness Hearing នៅថ្ងៃទី 24 ខែមករា ឆ្នាំ 2012 លោកអ្នក**ត្រូវតែ**និយាយនៅក្នុងសំបុត្ររបស់លោកអ្នក ។ វាសំរេចលើតុលាការដែលនឹងអនុញ្ញាតឲ្យអ្នកឬមិនឲ្យដើម្បីនិយាយនៅក្នុងសវនាការ ។ ម៉្យាងទៀត លោកអ្នកមិនត្រូវតែបង្ហាញខ្លួននៅក្នុងតុលាការនៅថ្ងៃទី 24 ខែមករា ឆ្នាំ 2012 ដើម្បីឲ្យការតវ៉ារបស់លោកអ្នកទទួលការពិចារណាឡើយ ។

### 15. បើការផ្សះផ្សាត្រូវបានអនុម័ត តើវាមានន័យយ៉ាងដូចម្តេច ?

បើការផ្សះផ្សានេះត្រូវបានអនុម័ត លោកអ្នកអាចទទួល CBAS ឬការគ្រប់គ្រងសំណុំរឿងប្រសើរឡើង អាស្រ័យលើស្ថានភាពរបស់លោកអ្នក ។ លោកអ្នកមិនអាចរួមចំណែកនៅក្នុងបណ្តឹងមួយទៀត ស្តីអំពីបញ្ហាថា តើរដ្ឋ California អាចបញ្ចប់អត្ថប្រយោជន៍ Medi-Cal ADHC បាន ឬមិនបាននោះទេ ។

### 16. តើខ្ញុំប្រាប់តុលាការដោយរបៀបដូចម្តេច បើខ្ញុំមិនចូលចិត្តការផ្សះផ្សានេះ ?

បើលោកអ្នកជាសមាជិកក្រុម លោកអ្នកអាចប្រាប់តុលាការថាលោកអ្នកមិនយល់ស្របនឹងការផ្សះផ្សា ឬជាមួយផ្នែកណាមួយនៃការផ្សះផ្សា ដោយផ្ញើសំបុត្រដែលមានការតវ៉ារបស់លោកអ្នក ឲ្យបានទាន់ថ្ងៃទី 10 ខែមករា ឆ្នាំ 2012 ។

# NOTICE OF CLASS ACTION SETTLEMENT AGREEMENT
# (សេចក្តីជូនដំណឹងអំពីកិច្ចព្រមព្រៀងផ្សះផ្សាបណ្តឹងតាងនាមក្រុម)
# *Darling et al. v. Douglas et al.,* C09-03798 SBA

លោកអ្នកអាចសរសេរសំបុត្រដោយខ្លួនឯង ឬតាមរយៈមេធាវីដោយបង់ថ្លៃខ្លួនឯងក៏បាន ។

ដើម្បីតវ៉ា លោកអ្នកត្រូវតែផ្ញើសំបុត្រមួយទៅកាន់តុលាការ និយាយថាលោកអ្នកតវ៉ា ហើយពន្យល់ហេតុផលសំរាប់ការតវ៉ារបស់លោកអ្នក ។ នៅខាងលើសំបុត្រ ត្រូវប្រាកដដាក់ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទរបស់លោកអ្នក និងសរសេរ *Darling et al. v. Douglas et al.*; C09-03798 SBA ។ ត្រូវប្រាកដចុះហត្ថលេខាសំបុត្ររបស់លោកអ្នក ។

សូមផ្ញើសំបុត្រច្បាប់ដើមទៅកាន់ក្រឡាបញ្ជីតុលាការ (Clerk of the Court) ហើយផ្ញើសំណៅនៃសំបុត្រនោះទៅកាន់មេធាវីសំរាប់ភាគីទាំងឡាយ។ ការតវ៉ាត្រូវតែផ្ញើទៅកាន់កន្លែងទាំងបីនេះ ដោយបោះត្រាប្រៃសណីយ៍មិនហួសពីថ្ងៃទី **10 ខែមករា ឆ្នាំ 2012** ៖

| Clerk of the Court: | Attorneys for Class Members: | Attorneys for DHCS: |
|---|---|---|
| U.S. District Court<br>1301 Clay Street<br>Oakland, CA 94612<br><br>Reference: *Darling et al. v. Douglas et al.*, Case No. C09-03798 SBA | Elissa Gershon<br>Disability Rights California<br>1330 Broadway, Suite 500,<br>Oakland, CA 94612<br><br>ATTN: *Darling v. Douglas* | Susan M. Carson<br>Office of the Attorney General<br>455 Golden Gate Avenue,<br>Suite 11000<br>San Francisco, CA<br>94102-7004 |

### 17. តើតុលាការនឹងសម្រេចថាតើអនុម័ត ឬមិនអនុម័តការផ្សះផ្សានៅពេលណា និងនៅកន្លែងណា ?

តុលាការនឹងធ្វើ Fairness Hearing មួយ ដើម្បីសម្រេចថាតើអនុម័ត ឬមិនអនុម័តការផ្សះផ្សា នៅ **ថ្ងៃទី 24 ខែមករា ឆ្នាំ 2012 នៅវេលាម៉ោង 1 រសៀល** ។ តុលាការនឹងពិចារណាថា តើការផ្សះផ្សានេះប្រកបដោយយុត្តិធម៌ សមហេតុសមផល និងគ្រប់គ្រាន់ ឬទេ ។ ចៅក្រមនឹងស្តាប់សមាជិកក្រុមដែលបានស្នើសុំឡើងនិយាយនៅក្នុងសវនាការ ។ លោកអ្នកអាចចូលរួមបាន បើទោះជាលោកអ្នកមិនចង់និយាយក៏ដោយ ។ សវនាការនឹងប្រព្រឹត្តទៅនៅឯ ៖

United States District Court
Northern District of California
1301 Clay Street
Courtroom 1, 4th Floor
Oakland, CA 94612

### 18. តើអ្វីនឹងកើតឡើងបើខ្ញុំមិនធ្វើអ្វីឡើយ ?

បើលោកអ្នកមិនធ្វើអ្វីឡើយ លោកអ្នកនឹងនៅតែជាសមាជិកក្រុម ។ បើការផ្សះផ្សានេះត្រូវបានអនុម័ត លោកអ្នកអាចទទួល CBAS ឬការគ្រប់គ្រងសំណុំរឿងប្រសើរឡើង អាស្រ័យលើស្ថានភាពរបស់លោកអ្នក ។ លោកអ្នកនឹងមិនអាចរួមចំណែកនៅក្នុងបណ្តឹងមួយទៀត ស្តីអំពីបញ្ហាថាតើរដ្ឋ California អាចបញ្ចប់អត្ថប្រយោជន៍ Medi-Cal ADHC បាន ឬមិនបាននោះទេ ។

# NOTICE OF CLASS ACTION SETTLEMENT AGREEMENT
# (សេចក្តីជូនដំណឹងអំពីកិច្ចព្រមព្រៀងផ្សះផ្សាបណ្តឹងតាងនាមក្រុម)
# *Darling et al. v. Douglas et al.,* C09-03798 SBA

## <u>ការទទួលព័ត៌មានបន្ថែមទៀត</u>

### 19. តើខ្ញុំអាចទទួលព័ត៌មានលំអិតបន្ថែមទៀត ស្តីអំពីការផ្សះផ្សានេះបានយ៉ាងដូចម្តេច ?

ដើម្បីទទួលព័ត៌មានបន្ថែមទៀត សំណៅមួយច្បាប់នៃកិច្ចព្រមព្រៀងផ្សះផ្សា ឬជំនួយក្នុងការតវ៉ាទៅកាន់តុលាការ នោះលោកអ្នកអាចទាក់ទងអង្គការ Disability Rights California ៖

| | |
|---|---|
| darling@disabilityrightsca.org | (888) 599-3921 |

### 20. តើខ្ញុំអាចទទួលព័ត៌មានបន្ថែមទៀតអំពីរឿងក្តីនេះបានយ៉ាងដូចម្តេច ?

លោកអ្នកអាចទទួលព័ត៌មានបន្ថែមទៀតអំពីរឿងក្តី ដោយមើលសំណុំរឿងក្តីនៅក្នុងការិយាល័យនៃ Clerk of the U.S. District Court នៅអាសយដ្ឋានដែលរាយនៅក្នុងសំនួរលេខ 17 ។ លោកអ្នកក៏អាចមើលកិច្ចព្រមព្រៀងផ្សះផ្សាទាំងមូល ហើយទទួលព័ត៌មានបន្ថែមទៀត នៅឯ ៖

- http://www.disabilityrightsca.org/advocacy/Darling-v-Douglas/index.html

  **ឬ**
- http://www.dhcs.ca.gov/services/medi-cal/Pages/ADHC/ADHC.aspx

### 21. តើធ្វើដូចម្តេចដើម្បីទទួលសំណៅមួយច្បាប់នៃសេចក្តីជូនដំណឹងនេះ ជាភាសាផ្សេងទៀត ឬជាទ្រង់ទ្រាយដែលសម្រួលដល់ជនមានពិការភាព ?

បើលោកអ្នកត្រូវការសំណៅមួយច្បាប់នៃសេចក្តីជូនដំណឹងនេះជាភាសាផ្សេងទៀត ឬមានពិការភាពហើយត្រូវការការសម្រួល ដូចជាសេចក្តីជូនដំណឹងជាទ្រង់ទ្រាយផ្សេងទៀត (ឧទាហរណ៍ អក្សរអ្នកខ្វាក់ ឬអក្សរធំ) ឬវិធីផ្សេងមួយទៀត ដើម្បីសួរសំនួរអំពីសេចក្តីជូនដំណឹង (ឧទាហរណ៍ អ្នកបកប្រែភាសាកាយវិការអ្នកថ្លង់) នោះលោកអ្នកអាច ៖

- ទាក់ទងមេធាវីខាងភាគីដើមចោទ គឺអង្គការ Disability Rights California តាមលេខ (888) 599-3921;

**ឬ**

- មើលវ៉ិបសៃត៍របស់អង្គការ Disability Rights California ឬក្រសួង DHCS ដែលមាននៅក្នុងសំនួរលេខ 20 ។